# លោក ហួន ផន៖សេរីភាពសារព័ត៌មាននៅកម្ពុជាមិនទាន់ល្អប្រសើរ




នៅថ្ងៃទី២៦ ខែវិច្ឆិកានេះ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា(CCHR) បានចេញរបាយការណ៍មួយស្តីពីសេរីភាពបញ្ចេញមតិ សេរីភាពសារព័ត៌មាន និងសិទ្ធិទទួលបានព័ត៌មាននៅកម្ពុជា ពីខែកញ្ញា ឆ្នាំ ២០២៣ ដល់ខែសីហា ឆ្នាំ ២០២៤។ តាមរបាយការណ៍ អ្នកសារព័ត៌មាន ដែលបានប្រឈមនឹងផ្លូវច្បាប់ដោយសារការបំពេញវិជ្ជាជីវៈរបស់ខ្លួនមាន ១៧ករណី។ ចំនួននេះបានកើនឡើង ១ករណី បើធៀបនឹងឆ្នាំ ២០២៣។ ក្នុងបទសម្ភាសផ្ទាល់ជាមួយវិទ្យុបារាំងអន្តរជាតិ RFI  លោក ហួន ផន អ្នកសម្របសម្រួលគម្រោងនៃ CCHR កត់សម្គាល់ថា សេរីភាពសារព័ត៌មាននៅកម្ពុជាមិនទាន់ល្អប្រសើរនៅឡើយទេ៕